# សេចក្តីថ្លែងការណ៍ព័ត៌មាន

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ – អង្គការតម្លាភាពកម្ពុជាចេញផ្សាយនូវរបាយការណ៍ស្រាវជ្រាវនៃការស្ទង់មតិថ្នាក់ជាតិស្តីពី "គណនេយ្យភាព និងតម្លាភាពនៃដំណើរការថវិកា"។ ការស្ទង់មតិថ្នាក់ជាតិនេះមានគោលដៅស្វែងយល់ និងប៉ាន់ប្រមាណពីការយល់ឃើញ និងឥរិយាបថរបស់ប្រជាពលរដ្ឋចំពោះតម្លាភាព និងគណនេយ្យភាពថវិកាក្នុងប្រទេសកម្ពុជា ក៏ដូចជាការយល់ដឹង និងបទពិសោធន៍របស់ពួកគេពាក់ព័ន្ធជាមួយថវិកា និងបញ្ហាថវិកាក្នុងប្រទេសកម្ពុជា។ ការសិក្សានេះត្រូវបានធ្វើឡើងក្នុងខែតុលា ឆ្នាំ២០១៧ តាមរយៈការអនុវត្តវិធីសាស្ត្រជ្រើសរើសសំណាកបែបចៃដន្យ និងបានធ្វើកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋចំនួន ១,៥៩៦ នាក់ ក្នុងភូមិចំនួន ២០០ ស្ថិតក្នុងឃុំចំនួន ១០០ នៅក្នុងរាជធានី ខេត្តទាំង ២៥ ទូទាំងប្រទេសកម្ពុជា។

លទ្ធផលរកឃើញនៃការស្ទង់មតិនេះត្រូវបានបែងចែកជាពីរផ្នែកគឺ ការបង្ហាញទិន្នន័យនៃការស្ទង់មតិសម្រាប់កម្រិតថ្នាក់ជាតិ និងថ្នាក់ឃុំ សង្កាត់។ លទ្ធផលនៃការស្ទង់មតិនេះបានរកឃើញថា ចំណេះដឹងស្តីពីដំណើរការថវិកា លទ្ធភាពក្នុងការទទួលបានព័ត៌មានថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការថវិកាថ្នាក់ជាតិ ក៏ដូចជាថ្នាក់ឃុំ សង្កាត់ ជាទូទៅគឺមានកម្រិតទាបនៅឡើយ។ ការវិភាគនេះក៏បានកត់សម្គាល់ផងដែរថា កត្តាដែលជះឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធផលរកឃើញនេះរួមមាន៖ កត្តាសង្គមប្រជាសាស្ត្រ សង្គមសេដ្ឋកិច្ច យេនឌ័រ ការអប់រំ និងកត្តាភូមិសាស្ត្រ។

លទ្ធផលនៃការយល់ដឹងរបស់សាធារណជនអំពីដំណើរការថវិកាបានបង្ហាញនូវភាពព្រួយបារម្ភយ៉ាងខ្លាំង។ ជាក់ស្តែង ប្រជាពលរដ្ឋត្រឹមតែ ០.៣%ប៉ុណ្ណោះ ដែលអាចប្រាប់បានយ៉ាងត្រឹមត្រូវអំពីទំហំថវិកាជាតិឆ្នាំ២០១៧។ ចំពោះការយល់ដឹងទាក់ទងនឹងចំណូល និងចំណាយថវិកាថ្នាក់ជាតិវិញ ប្រជាពលរដ្ឋប្រមាណ ៣៣.៤% ពុំដឹងថាប្រភពចំណូលរបស់រាជរដ្ឋាភិបាលកម្ពុជាបានមកពីណាឡើយ ខណៈដែល ៤៦.៤% ពុំដឹងថារដ្ឋបាភិបាលចំណាយថវិកាថ្នាក់ជាតិទៅលើវិស័យចម្បងណាខ្លះឡើយ។ ចំណែកឯ ចំណេះដឹងរបស់សាធារណជនទាក់ទងនឹងដំណើរការថវិកាថ្នាក់ឃុំ សង្កាត់ ជាទូទៅគឺមានអត្រាខ្ពស់ជាងចំណេះដឹងស្តីពីដំណើរការថវិកាថ្នាក់ជាតិ។ ប្រជាពលរដ្ឋ ៣៧.៥% ដឹងថាអ្នកដែលមានតួនាទីចម្បងក្នុងការរៀបចំថវិកាឃុំ សង្កាត់។

ទន្ទឹមគ្នានេះ លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងថវិកាជាតិ ក៏បានបង្ហាញនូវបញ្ហាដ៏គួរឱ្យបារម្ភផងដែរ។ មានប្រជាពលរដ្ឋត្រឹមតែ ០.១%ប៉ុណ្ណោះ ដែលធ្លាប់បានឃើញឯកសារផ្លូវការរបស់រដ្ឋាភិបាលស្តីពីថវិកាជាតិ ហើយមានត្រឹមតែ ១.១% ដែលធ្លាប់ព្យាយាមស្វែងរកមើលឯកសារស្តីពីថវិកាជាតិ។ ស្រដៀងគ្នានេះដែរ លទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានថវិកាឃុំ សង្កាត់ គឺមានកម្រិតទាប ដោយប្រជាពលរដ្ឋជាច្រើនពុំបានដឹងថា ព័ត៌មានថវិកាត្រូវបានរក្សាទុកដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនឡើយ។ ប្រជា-

ពលរដ្ឋរហូតដល់ ៩០.២% ឆ្លើយថាមិនធ្លាប់បានទទួលព័ត៌មានណាមួយពីអាជ្ញាធរឃុំ សង្កាត់អំពីការផ្សព្វផ្សាយនូវព័ត៌មានថវិកាឡើយ។ ហើយប្រជាពលរដ្ឋ ៩៦.៥% មិនធ្លាប់បានព្យាយាមស្វែងរកមើលព័ត៌មានថវិកាឃុំ សង្កាត់ឡើយ។ ដោយឡែក ប្រជាពលរដ្ឋក៏បានបង្ហាញការគាំទ្រយ៉ាងខ្លាំង ដើម្បីឱ្យមានការទទួលបានព័ត៌មានថវិកាកាន់តែទាន់ពេលវេលា និងមានតម្លាភាពថែមទៀត។ ប្រជាពលរដ្ឋប្រមាណ ៩៨.៥% ជឿថា ព័ត៌មានថវិកាជាតិគួរតែរៀបចំឱ្យសាធារណជនទូទៅមានលទ្ធភាពទទួលបានច្រើន និងងាយយល់សម្រាប់សាធារណជនទូទៅបន្ថែមទៀត។

មិនខុសពីការយល់ដឹង និងការទទួលបានព័ត៌មានស្តីពីថវិកានោះទេ ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការថវិកាថ្នាក់មូលដ្ឋាន ក៏បានចោទជាបញ្ហាគួរឱ្យកត់សម្គាល់ផងដែរ។ មានត្រឹមតែ២៨.៦% ប្រជាពលរដ្ឋបានធ្លាប់ចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំសម្រាប់ផែនការអភិវឌ្ឍឃុំ សង្កាត់ កម្មវិធីវិនិយោគ និងការរៀបចំថវិកា។ ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋ ៩១% គិតថា ការចូលរួមរបស់សាធារណជនកាន់តែច្រើននឹងធ្វើឱ្យមានគុណភាពនៃសេវានានានឹងប្រសើរជាងមុន។ ចំពោះបុគ្គលដែលពុំបានចូលរួមក្នុងដំណើរការទាំងនោះអះអាងថា កង្វះការលើកទឹកចិត្តឱ្យចូលរួម និងកង្វះខាតនៃការផ្សព្វផ្សាយព័ត៌មានអំពីឱកាសក្នុងការចូលរួម គឺជាកត្តារារាំងពួកគាត់មិនអាចចូលរួមបាន។

អង្គការតម្លាភាពកម្ពុជាសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបញ្ជ្រាបព័ត៌មានដល់សាធារណជនអំពីដំណើរការថវិកាកម្រិតថ្នាក់ជាតិ និងថ្នាក់ឃុំ សង្កាត់។ ការបង្កើននូវចំណេះដឹងរបស់សាធារណជន នឹងមិនត្រឹមតែអាចបង្កើតភាពជាម្ចាស់ការកាន់តែច្រើនទាក់ទងនឹងដំណើរការថវិកាជាទូទៅប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយដ៏ចាំបាច់មួយដើម្បីសម្រេចបាននូវអនុសាសន៍ដទៃទៀតដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះផងដែរ។ រាជរដ្ឋាភិបាលថ្នាក់ជាតិក៏គួរតែបង្កើនលទ្ធភាពក្នុងការទទួលបានព័ត៌មានស្តីពីថវិកាសម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីឆ្លើយតបទៅតាមការចាប់អារម្មណ៍ដ៏ខ្លាំងរបស់ពួកគាត់ទាក់ទងនឹងថវិកា និងហិរញ្ញ-វត្ថុជាតិ។ យ៉ាងណាក៏ដោយ ការបិតផ្សាយព័ត៌មានគឺមិនគ្រប់គ្រាន់ឡើយ។ រាជរដ្ឋាភិបាលក៏គួរតែពិចារណាផងដែរទៅលើរបៀបដែលព័ត៌មានទាំងនេះត្រូវបានរៀបចំ និងបង្ហាញ ក៏ដូចជារបៀបដែលវាត្រូវបានចែកចាយ និងផ្សព្វផ្សាយជាដើម ដើម្បីធានាបាននូវការបញ្ជ្រាបបានទូលំទូលាយ និងលទ្ធភាពក្នុងការទទួលបានព័ត៌មាន។ ម្យ៉ាងវិញទៀតរដ្ឋាភិបាលគួរបង្កើនកម្មវិធីផ្សព្វផ្សាយតាមមូលដ្ឋាន និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួម នៅក្នុងដំណើរការរៀបចំថវិកាកាន់តែច្រើនថែមទៀត។

លោក ព្រាប កុល នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជាមានប្រសាសន៍ថា៖ *ការសិក្សាស្រាវជ្រាវនេះបានផ្តល់ជាកស្តុតាងជូនដល់ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាដៃគូអភិវឌ្ឍន៍នានាដែលមានបំណងស្វែងយល់ឱ្យស៊ីជម្រៅបន្ថែមទៀតអំពីការយល់ឃើញ និងឥរិយាបថរបស់ប្រជាពលរដ្ឋចំពោះបញ្ហាថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេសកម្ពុជា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។*

*ជាលទ្ធផល  ក៏ដូចជាចំណេះដឹងទាំងនេះអាចជួយពួកគាត់ក្នុងការបង្កើត  ឬធ្វើកំណែទម្រង់គោលនយោបាយ  និង កម្មវិធីនានា ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពថវិកាឱ្យកាន់តែប្រសើរថែមទៀត។*

<u>សម្រាប់ការធ្វើបទសម្ភាសន៍សូមទំនាក់ទំនង៖</u>

លោក **ព្រាប កុល** នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា ទូរស័ព្ទលេខ ០១២ ៨៧៧ ៨៣៣
ឬតាមរយៈអ៊ីម៉ែល kolpreap@ticambodia.org

###

*អង្គការតម្លាភាពកម្ពុជា គឺជាសាខាប្រចាំប្រទេសរបស់អង្គការតម្លាភាពអន្តរជាតិ ដែលឈរលើជំហរអព្យាក្រឹត្យ និង ឯករាជ្យ ហើយឈានមុខក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ អង្គការតម្លាភាពកម្ពុជាមានបេសកកម្មធ្វើការ ជាមួយស្ថាប័ននានា រួមទាំងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជន ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត និង ប្រជាពលរដ្ឋទូទៅ ដើម្បីលើកកម្ពស់តម្លាភាព សុចរិតភាព គណនេយ្យភាព និងកាត់បន្ថយអំពើពុករលួយនៅក្នុង ប្រទេសកម្ពុជា។*